# ទន្សាយបកស្រាយ
# ពីសិទ្ធិកុមារ



unicef

# ទន្សាយបកស្រាយ ពីសិទ្ធិកុមារ



សំគាល់: នៅក្នុងសាច់រឿង ពាក្យដែលមានសំគាល់ដោយសញ្ញា * មានពន្យល់ពាក្យនៅទំព័រចុងក្រោយ




# សូមស្វាគមន៍

ក្មួយៗដែលកំពុងអានសៀវភៅរឿង
"ទន្សាយបកស្រាយពីសិទ្ធិកុមារ"។

កុមារគ្រប់រូបនៅប្រទេសកម្ពុជាមានសិទ្ធិមនុស្សដូចៗគ្នា ដើម្បីរស់រានមានជីវិត លូតលាស់ និងអភិវឌ្ឍពេញលេញ ចៀសផុតពីអំពើហិង្សា ការរំលោភបំពាន និងការបោះបង់ចោល។ កុមារក៏មានសិទ្ធិចូលរួម ក្នុងជីវិតគ្រួសារ វប្បធម៌ និងសង្គមដែរ។ នៅឆ្នាំ ១៩៩២ ប្រទេស កម្ពុជាបានយល់ព្រមគោរពសិទ្ធិកុមារ។ សិទ្ធិកុមារទាំងអស់មានចែងនៅក្នុង "អនុសញ្ញា អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ"។

សិទ្ធិដើរទន្ទឹមនឹងការទទួលខុសត្រូវ។ មនុស្សគ្រប់រូបត្រូវគោរពសិទ្ធិ របស់ក្មួយ ហើយក្មួយក៏ត្រូវគោរពសិទ្ធិរបស់គេដែរ។ ក្មួយមានសិទ្ធិ។ ឪពុកម្តាយ និងលោកគ្រូអ្នកគ្រូក្មួយក៏មានសិទ្ធិដែរ។

នៅក្នុងសៀវភៅនេះ ក្មួយនឹងរៀនអំពីសិទ្ធិកុមារ។ វានឹងជួយរៀបចំ ក្មួយឲ្យក្លាយទៅជាពលរដ្ឋម្នាក់ ដែលចេះយកចិត្តទុកដាក់ដល់អ្នកដទៃ និងមានការទទួលខុសត្រូវ។

សូមក្មួយៗអានសៀវភៅដោយរីករាយ និងនិយាយរឿងនេះប្រាប់បន្តដល់មិត្តភ័ក្រ្ត បងប្អូន ក្រុមគ្រួសារ ឪពុកម្តាយ និងលោកគ្រូ អ្នកគ្រូ។



លោកស្រី រ៉ាណា ផ្លាវើ
នាយិកាអង្គការយូនីសេហ្វ
ប្រចាំកម្ពុជា


សួស្តីក្មេងៗ!
យី ទន្សាយ ចេះនិយាយ!
បានជួបអីចឹងល្អណាស់។ បងនឹងបង្ហាញពីរឿងសិទ្ធិ ដល់ពួកប្អូន ចង់ស្តាប់ទេ?



សិទ្ធិនោះជាអ្វីទៅ?
មនុស្សគ្រប់រូបកើតមកសុទ្ធតែមានសិទ្ធិនេះ គឺសិទ្ធិទទួលបានសេរីភាព យុត្តិធម៌* និងសន្តិភាពក្នុងពិភពលោក។
ចេកខ្ញុំមានច្រើនណាស់បងយកញ៉ាំខ្លះចុះ។ សិទ្ធិមនុស្សបែបមានមិនច្រើនដូច ផ្លែចេកខ្ញុំទេ គឺសំរាប់ តែចាស់ៗទេដឹង?
ទេ ក្មេងៗក៏មានសិទ្ធិដែរ!
ពិតមែនឬ?
ពិតណាស់! មនុស្សទាំងអស់មានសិទ្ធិដូចៗគ្នា លើសពីនេះក្មេងៗមានសិទ្ធិជាពិសេសទៀតផង។


ហេតុអ្វីបានជាក្មេង
ត្រូវមានសិទ្ធិពិសេស?
ក្មេងត្រូវមាន
សិទ្ធិពិសេស
ពីព្រោះពួកគេ
នៅតូច ដូច្នេះ
ត្រូវការកិច្ច
គាំពារច្រើនជាង
មនុស្សចាស់។
គេមិនប្រកាន់ថា
ក្មេងនោះមាន ឬក្រ
មានពូជសាសន៍*
សាសនា*
និងពណ៌សំបុរ*
បែបណាឡើយ។
ហើយគេក៏មិន
ប្រកាន់ថា ជាក្មេង
ប្រុស ឬក្មេងស្រីដែរ។
ក្មេងទាំងអស់មាន
សិទ្ធិដូចៗគ្នា។
តើប្អូនចង់សួរអ្វីទៀត
ទាក់ទងពីរឿងសិទ្ធិនោះ?


ខ្ញុំចង់ដឹងណាស់ តើសិទ្ធិអ្វីខ្លះ ដែលខ្ញុំមាន?
បងកំពុងចង់ប្រាប់ពួកប្អូនហ្នឹងហើយ! បងសុំជិះកង់ផង។ បងនឹងប្រាប់រឿងនេះដល់ប្អូនៗតាមផ្លូវ។
សាលាឃុំ
ពួកប្អូនត្រូវស្វែងយល់ពីសិទ្ធិរបស់ខ្លួនអោយបានច្បាស់។ ប្អូននឹងក្លាយទៅជាក្មេងឆ្លាតហើយពូកែ ហើយអាចដឹងថា គេគោរពសិទ្ធិពួកប្អូនដែរឬអត់។
អាឡូព្រាប! សុំយកឯកសារសិទ្ធិកុមារមកមុខសាលាឃុំអោយលឿនណា៎! ខ្ញុំចាំឯងនៅទីនេះ!


អ្នកមានអាយុក្រោម ១៨ឆ្នាំគឺជាកុមារ។
កុមារគឺជាមនុស្សដែលមានអាយុតិចជាង១៨ឆ្នាំ។
មីង ចាន់យកអាអូនទៅណាហ្នឹង?
មីងនាំវាមកចុះសំបុត្រកំណើត។ មីងចូលក្នុងសិនហើយណា៎!
ការចុះសំបុត្រកំណើតមានសារៈសំខាន់អ្វីខ្លះ?
កុមារមានសិទ្ធិទទួលសំបុត្រកំណើត សញ្ជាតិ និងឈ្មោះ។
សំបុត្រកំណើតជួយបញ្ជាក់អោយច្បាស់ថា ប្អូនជានរណា។


ពេលគ្រប់អាយុទៅសាលា ប្អូនត្រូវការវាជាចាំបាច់សំរាប់ ចុះឈ្មោះចូលរៀន។ វាអាច ការពារពួកប្អូនអោយផុតពីការបង្ខំ អោយរៀបការ និងបង្ខំអោយ ធ្វើការមុនពេលគ្រប់វ័យ។
យី ហើយចុះក្មេងៗ ទៅណាទៀតហើយ?!
ពួកឯង មានឃើញ មីងទេ?
បាទ! មីងទើបតែចូល ទៅមុននេះបន្តិច។
ពូសានយកចិត្ត ទុកដាក់នឹងប្រពន្ធ កូនគាត់ណាស់។
តស់ ទៅរៀន សិទ្ធិកុមារ ជាមួយបង ទន្សាយ ទៀត!
គ្រួសារកុមារមានកាតព្វកិច្ច * ការពារនិងថែទាំកុមារ។
ឪពុកម្តាយយើងគួរធ្វើយ៉ាង នេះហើយ ប៉ុន្តែតើរដ្ឋាភិបាលគួរ ជួយអ្វីបានខ្លះដែរទេ?
រដ្ឋាភិបាលគួរជួយគាំទ្រ ដល់ឪពុកម្តាយ និងក្រុម គ្រួសារកុមារ។ ម្យ៉ាងទៀត គ្មាននរណាអាចបំបែកកុមារ ចេញពីគ្រួសារផ្ទុយពីបំណង ពួកគេឡើយលើកលែងតែ ពួកគេត្រូវក្រុមគ្រួសារ ធ្វើបាប។


មីងទៅ មុនហើយ ណា៎ ព្រោះ ត្រូវយក អាតូច ទៅចាក់ថ្នាំ ការពារជំងឺ ទៀត។
ចាស៎ មីង
បា៎ទ មីង


មើលនេះនែ៎!
ប្រសិនបើកុមារពុំមាន
ឪពុកម្ដាយ ឬមិនអាច
រស់នៅជាមួយគ្រួសារ
បាន រដ្ឋាភិបាលត្រូវតែ
ការពារកុមារហើយត្រូវ
ធ្វើអោយកុមារទទួល
បានការថែទាំហ្មត់ចត់
យ៉ាងពិតប្រាកដ។
ចុះការទទួលចិញ្ចឹមក្មេងនោះ តើយ៉ាងណាដែរ?
រដ្ឋាភិបាល* ត្រូវប្រាកដថា អ្នកដែល សុំក្មេងទៅចិញ្ចឹមនោះគឺជាមនុស្សល្អ។









**កុមារមានសិទ្ធិទទួលការព្យាបាលជំងឺ និងការពារសុខភាពដោយឥតគិតថ្លៃ។**

**កុមារមានសិទ្ធិទទួលម្ហូបអាហារ សំលៀកបំពាក់និងជំរកគ្រប់គ្រាន់ ដើម្បីអោយកុមារអាចរីកធំធាត់បាន។**


តស់ យើង ទៅមុខទៀត!
យី កង់យើងធូរ បែកឡាត់ទៅហើយ!


មើលនុ៎ះ បងទន្សាយ! ពួកគេទាំងនោះ ក្រខ្លាំងណាស់។







**មិនត្រូវចាប់ពង្រត់
លក់កុមារ ឬយក
កុមារទៅបរទេស
ដោយខុសច្បាប់ទេ។
នេះគឺជាបទឧក្រិដ្ឋ *។**







ត្រូវបងទន្សាយហើយ ឈឺខ្លាំងទេបង?
គ្របឆ្នាំងហោះចេញពីកន្លែង ឈ្លោះគ្នានៅខាងនោះន៎!
ឈឺគ្រាន់បើដែរ តែដោយអចេតនាទេ យើងកុំប្រកាន់អី! ប៉ុន្តែបើមានគេចង់ វាយធ្វើបាបប្អូនបែបនេះ មានន័យថាខុស ច្បាប់ហើយ។
គេមិនត្រូវ វាយដំ ធ្វើបាប ឬរំលោភបំពាន លើកុមារទេ។
បើយើងរងគ្រោះ តើ គេគួរមើល ថែយើង យ៉ាងម៉េចខ្លះទៅ?
គេត្រូវជួយ សង្គ្រោះពួកប្អូន អោយច្រើនបំផុត តាមដែលអាចធ្វើ បាន ដើម្បីអោយពួក ប្អូនជាសះស្បើយទាំង ផ្លូវកាយនិងផ្លូវចិត្ត។


បងដឹងទេ នៅភូមិខ្ញុំ មានបងស្រីម្នាក់ គួរអោយអាណិតណាស់ គាត់ត្រូវឪពុកខ្លួនឯងចាប់រំលោភ។ តើសិទ្ធិមានការពារយើងក្នុងរឿងនេះដែរ ឬទេ?
គ្មាននរណាអាចប៉ះពាល់ខ្លួនប្រាណប្អូន នៅកន្លែងដែលប្អូន មិនចង់អោយគេប៉ះនោះឡើយ ទោះ អ្នកនោះជាឪពុកម្តាយ មាមីង ញាតិមិត្ត ឬនរណាដែលប្អូនស្គាល់ជិតដិតក៏ដោយ។
កុមារមានសិទ្ធិទទួលកិច្ចគាំពារអោយរួចផុតពីពេស្យាចារ * ការរំលោភបំពានផ្លូវភេទ និងអំពើអាសអាភាស។
បើមានរឿងដូច្នេះកើតឡើង ចូរប្រាប់រឿងនោះទៅអ្នកដទៃ និងសុំអោយគេជួយការពារប្អូន។ ហើយសូមចងចាំថា នោះមិនមែនជាកំហុសរបស់ប្អូននោះទេ។


បើកុមារពិការ កុមារក៏មានសិទ្ធិរៀនសូត្រ និងកំសាន្តសប្បាយជាមួយនឹងកុមារដទៃទៀត។ កុមារមានសិទ្ធិគោរពដល់វប្បធម៌ * សាសនា និងនិយាយភាសារបស់គេដោយសេរី បើទោះជាកំណើតដើមរបស់កុមារជាអ្វីក៏ដោយ។
តើនរណាខ្លះជាអ្នកទទួលបន្ទុក និងជួយក្មេងពិការ?
ក្រៅពីឪពុកម្ដាយ និងក្រុមគ្រួសារពួកគេ យើងក៏គួរចូលរួមផ្ដល់កំលាំងចិត្ត និងការយកចិត្តទុកដាក់ចំពោះក្មេងទាំងនោះផងដែរ។ ខ្ញុំថាត្រូវទេបងទន្សាយ?
ត្រូវហើយ! ប៉ុន្តែ ស្ថាប់ណាំ រដ្ឋាភិបាលក៏ជាផ្នែកមួយដ៏សំខាន់ ដែលត្រូវរ៉ាប់រងបន្ទុកនេះដែរ។


កុមារមានសិទ្ធិការពារខ្លួនអោយផុត
ពីការសេពគ្រឿងញៀនដ៏គ្រោះថ្នាក់។
ពួកប្អូនដែលឃើញអ្នកជក់គ្រឿងញៀនទេ?
អត់ដែលឃើញទេ!
គ្រឿងញៀនជាអ្វីទៅបងទន្សាយ?
គ្រឿងញៀនធ្វើអោយមានគ្រោះថ្នាក់ដល់យើង។ វានឹងបំផ្លាញរាងកាយ និងខួរក្បាលរបស់អ្នកជក់ ឬហិតវា។
យី ទន្សាយចេះនិយាយហ្ន៎!



មិនត្រូវអោយកុមារធ្វើការច្រើនម៉ោង ដែលធ្វើអោយកុមារ
មិនបានទៅរៀន ឬធ្វើការងារធ្ងន់ ដែលអាចនាំអោយមាន
គ្រោះថ្នាក់ដល់សុខភាព និងការរីកលូតលាស់របស់កុមារ។




ខ្ញុំសុំសួររឿង មួយបានទេ?
សួរមកចុះ!
ពេលមាន សង្គ្រាម តើយើង ត្រូវទៅច្បាំងឬទេ?
ព្រាបអើយ សុំយកឯកសារ មក!
គេមិនត្រូវជ្រើសរើសកុមារអាយុក្រោម១៨ឆ្នាំអោយធ្វើទាហានទេ ពីព្រោះពួកគេ ស្ថិតនៅក្នុងវ័យកុមារ ដែលត្រូវការនូវកិច្ចការពារពិសេស។ ម្យ៉ាងទៀតរូបរាងកាយ និង ប្រាជ្ញាស្មារតីរបស់ពួកគេ ក៏នៅមិនទាន់ពេញវ័យដែរ។
មិនត្រូវប្រើកុមារដែល មានអាយុក្រោម១៨ឆ្នាំ សំរាប់ប្រយុទ្ធក្នុងសង្គ្រាមទេ។


ម្សិលមិញ នៅក្បែរផ្ទះខ្ញុំមានក្មេងម្នាក់ ខឹងឪចុងធ្វើបាបខ្លាំងពេក ក៏លបច្រានគាត់ ធ្លាក់ជណ្តើរ ស្លាប់បាត់ទៅ តើក្មេងនោះត្រូវ ជាប់គុកទេ បងទន្សាយ?
រឿងហ្នឹងក៏មានចែងក្នុងសិទ្ធិកុមារដែរ នោះ ព្រាបមកដល់ល្មម។


ប្រសិនបើកុមារបានប្រព្រឹត្តិបទឧក្រិដ្ឋ គេមិនត្រូវផ្តន្ទាទោសកុមារអោយជាប់គុកមួយជីវិត ឬប្រហារជីវិតឡើយ។
ទោះជាយ៉ាងនេះក្តី ពួកខ្ញុំនឹងមិនប្រព្រឹត្តិបទឧក្រិដ្ឋទេ។ ធ្វើបាបគេ ខ្ញុំខ្លាចមានកម្មពៀរណាស់។







កុមារមានសិទ្ធិលេង
និងចូលរួមក្នុងផ្នែក
តន្ត្រី ចំរៀង របាំ ល្ខោន
សិល្បៈ ការច្នៃប្រឌិត
និងសកម្មភាព
វប្បធម៌ផ្សេងៗ។




សប្បាយណាស់ ខ្ញុំខានលេងដូច្នេះយូរមកហើយ...!
....ហើយក៏ខានទៅសាលាជាយូរមកហើយដែរ។ ពុកម៉ែខ្ញុំក្រ ខ្លាំងណាស់ ខ្ញុំត្រូវធ្វើការងារជាច្រើន ដើម្បីជួយរកលុយចិញ្ចឹមប្អូនៗ។


ក្នុងសិទ្ធិកុមារមាននិយាយពីរឿងរៀនដែរឬទេ បងទន្សាយ?
មាននិយាយនេះនែ៎...!


កុមារមានសិទ្ធិទៅសាលានិងសិក្សារៀនសូត្រដល់កំរិតខ្ពស់បំផុតតាមដែលអាចធ្វើបាន។
តាមធម្មតា រដ្ឋាភិបាលត្រូវខ្នះខ្នែងជួយបន្ថែមទៀត ដើម្បីអោយក្មេងៗបានទៅសាលាទាំងអស់គ្នាដូចជាការចុះឈ្មោះចូលរៀនមិនបង់ប្រាក់ជាដើម។






ត្រូវផ្តល់សេរីភាពក្នុង
ការនិយាយស្តីដល់កុមារ
ចំពោះរាល់បញ្ហាដែល
ប៉ះពាល់ដល់កុមារ។
សូមស្តាប់កុមារដោយ
យកចិត្តទុកដាក់។




តើក្មេងៗ ទាំងអស់មាន សិទ្ធិដូចៗគ្នា ឬយ៉ាងណា?
ប្រាកដណាស់! សិទ្ធិគឺមានដូចគ្នាសំរាប់ក្មេងទាំងអស់ មិនថាគេជានរណា រស់នៅទីណា និយាយ ភាសាអ្វី មានវប្បធម៌ និងសាសនាខុសគ្នា ជាក្មេងស្រី ឬប្រុសក៏ដោយ។


ប៉ុន្តែ តើនរណាជាអ្នកធានាថា យើងនឹងមានសិទ្ធិនេះ?
គឺរដ្ឋាភិបាលរបស់ពួកប្អូន រួមទាំង ឪពុកម្តាយ គ្រួសារ និងសហគមន៍* ដែលពួកប្អូនរស់នៅ។
អ្នកទាំងនោះត្រូវជួយជ្រោមជ្រែង ដើម្បីអោយសិទ្ធិពួកប្អូនត្រូវគេគោរព និង ការពារ។ ប៉ុន្តែក្មេងៗ ខ្លួនឯងក៏ត្រូវប្រាកដ ក្នុងចិត្តថា ខ្លួនឯងមានសិទ្ធិនោះដែរ។


ពួកយើងត្រូវធ្វើយ៉ាងម៉េច ដើម្បីអោយប្រាកដក្នុងចិត្តថា យើងមានសិទ្ធិនោះ?
គឺត្រូវតែស្វែងយល់ពីសិទ្ធិ ពួកប្អូនៗអោយបានច្បាស់ ហើយត្រូវទាមទារអោយគេគោរពសិទ្ធិទាំងនោះ។
ប៉ុន្តែត្រូវចាំថា សិទ្ធិទាំងអស់តែងដើរទន្ទឹមគ្នានឹងការទទួលខុសត្រូវ។


ទទួលខុសត្រូវ? អ៊្ហា! វីវរហើយ បងកែវព្រឹកនេះយើងត្រូវយក ចេកទៅជូនយាយ!
មែនហើយ! បងភ្លេចអោយឈឹង។ តស់យើង អោយលឿនឡើង!


លាហើយ បងទន្សាយ!
លាហើយ ថ្ងៃក្រោយជួបគ្នាទៀតណា៎។

ចប់

# ពន្យល់ពាក្យ

- កាតព្វកិច្ច (ន) : កិច្ចការដែលត្រូវបំពេញ។
- បទឧក្រិដ្ឋ (ន) : បទល្មើសកំរិតធ្ងន់ ដូចជាការរំលោភ ការសំលាប់ជាដើម។ល។
- ពូជសាសន៍ (ន) : តំណជាតិសាសន៍ ឬវង្សត្រកូលរបស់ពួកមនុស្ស។
- ពេស្យាចារ (ន) : ការធ្វើជាមនុស្សលក់ខ្លួន គឺធ្វើការរួមភេទដើម្បីយកប្រាក់។
- យុត្តិធម៌ (ន) : ភាពត្រឹមត្រូវតាមច្បាប់។
- ពណ៌សំបុរ (ន) : ប្រភេទពណ៌ស្បែករបស់មនុស្ស មានដូចជា ស ខ្មៅ ជាដើម។
- រដ្ឋាភិបាល (ន) : ក្រុមមនុស្សអ្នកដឹកនាំប្រទេស។ នៅប្រទេសកម្ពុជា រដ្ឋាភិបាលមាននាយករដ្ឋមន្ត្រី និងក្រសួងទាំងអស់ដែលដឹកនាំរដ្ឋក្រោមការត្រួតពិនិត្យរបស់រដ្ឋសភា។
- វប្បធម៌ (ន) : ការបណ្តុះចំណេះវិជ្ជា និងប្រាជ្ញាស្មារតីអោយបានរីកចំរើនដោយវិទ្យាសាស្ត្រ ឬដោយសិល្បៈផ្សេងៗ។
- សាសនា (ន) : ជំនឿនិងការប្រតិបត្តិទាំងឡាយរបស់ពួកមនុស្សក្នុងការទាក់ទងជាមួយនឹងព្រះ។ ឧទាហរណ៍ សាសនាព្រះពុទ្ធ សាសនាអ៊ីស្លាម។ល។
- សហគមន៍ (ន) : ក្រុមមនុស្សដែលរស់នៅជាមួយគ្នា ឬមានផលប្រយោជន៍រួមគ្នា។

unicef
unite for children

មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ ( យូនីសេហ្វ )
ការិយាល័យប្រចាំប្រទេសកម្ពុជា
លេខ 11 ផ្លូវ 75 សង្កាត់ស្រះចក ខណ្ឌដូនពេញ
ប្រអប់សំបុត្រលេខ 176 រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : 023 426214/5
ទូរសារ : 023 426284
អ៊ីម៉ែល : phnompenh@unicef.org
គេហទំព័រ : www.unicef.org.kh
: UNICEF Cambodia

បោះពុម្ពឆ្នាំ 2014